**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៥)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៨ ៤៨៤ នាក់ នៃរោងចក្រ សហគ្រាស ទាំង៦៦ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ០០០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២០ ០០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦០ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៦៦ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃ អង្គារ ៧រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ២០២១*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

## ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២១

## បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៦៦ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 21 |
| 1 | ក្រុមហ៊ុន ជា ស៊ីណាត ហ្គាមេន ខូ អិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ថេកអូហ្វ (ខេមបូឌា) | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ដាប់ប៊ីលយូ អ៊ែនដ៍ ឌី កម្ពុជា | ភ្នំពេញ |
| 4 | ក្រុមហ៊ុន សាប ភ្នំពេញ ឯ.ក | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ឌូហ៊ីស្ត (ខេមបូឌា) | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ឃីង ហ្វេសិន ហ្គាមេន | ភ្នំពេញ |
| 7 | ក្រុមហ៊ុន វ៉ូដុងអ៊ីនដាសស្ទ្រៀល | ភ្នំពេញ |
| 8 | ក្រុមហ៊ុន អ៊ីអឹមប៊ី ដែលគូរី (ខេមបូឌា)ខូ.,អិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ស្កាយ ហាយ (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ហាំងតុងនីតវែរ (ខេមបូឌា) ឯ.ក | កណ្តាល |
| 11 | ក្រុមហ៊ុន វ៉ាយ អិម ជី ហ្គាមេន អេកសេសើរី | កណ្តាល |
| 12 | ក្រុមហ៊ុន អេហ្វ យូ ជី ហ្គាម៉ិន (ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុន អ៊ែដ្យាយល៍ ស្វេតធី(ខេមបូឌា)ខូ អិលធីឌី | កំពង់ស្ពឺ |
| 14 | ក្រុមហ៊ុន វីននីងដ្រាហ្គនឡេតធឺវែរ(ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 15 | ក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ(ខេមបូឌា)ខូ,.អិលធីឌី | កំពង់ឆ្នាំង |
| 16 | ក្រុមហ៊ុន ថប ស៊ុលវើរ លីមីធីត | ព្រៃវែង |
| 17 | ក្រុមហ៊ុន ហ្សូន (ខេមបូឌា) ត្រាវែលលីង & ហ៊ែនប៊ែក ឯ.ក | ព្រះសីហនុ |

| ល.រ | ឈ្មោះពេទចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 18 | ក្រុមហ៊ុន លីឌីង ស្តារ (ខេមបូឌា)ហ្គាមិន ឯ.ក | តាកែវ |
| 19 | ក្រុមហ៊ុន ហ្រ្គេសហ្វូល(ខេបូឌា)ថេកស្ថាយ ខូ.អិលធីឌី | តាកែវ |
| 20 | ក្រុមហ៊ុន ហៃលសា សៅ អ៊ិស អេស៊ា ខូអិលធីឌី | ស្វាយរៀង |
| 21 | ក្រុមហ៊ុន វ៉ុន ផេស្ទ័រ អ៊ីន | ស្វាយរៀង |
| ខ. វិស័យទេសចរណ៍ | | 45 |
| 22 | សណ្ឋាគារ អូឡាំព្យា ស៊ីធី ហូថេល | ភ្នំពេញ |
| 23 | ក្រុមហ៊ុន តារាអ៊ែរផត | ភ្នំពេញ |
| 24 | ក្រុមហ៊ុន អលមិន ខូ អិលធីឌី | ភ្នំពេញ |
| 25 | សណ្ឋាគារ រ៉េស៊ីដង់ សុខា ភ្នំពេញ | ភ្នំពេញ |
| 26 | ក្រុមហ៊ុន តូយ៉ូកូ អ៊ីន (ខេមបូឌា) | ភ្នំពេញ |
| 27 | ក្រុមហ៊ុន វីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 28 | ក្រុមហ៊ុន ខាល់ធី ស្ប៉ាយស៍(ខេមបូឌា)ខូ អិលធីឌី | ភ្នំពេញ |
| 29 | ក្រុមហ៊ុន សិប្បករអង្គរ | ភ្នំពេញ |
| 30 | ក្រុមហ៊ុន អេខ្ញីអេកស្ពឺឌីសិន (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 31 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 32 | ក្រុមហ៊ុន ស៊ីវ៉ាយ-អេសអ ហូថេល ហ្រ្គេន ឡាយអិន ឯ.ក | សៀមរាប |
| 33 | ភោជនីយដ្ឋានចាន់រីទ្រី | សៀមរាប |
| 34 | ភោជនីយដ្ឋានសុខៈរីវើ | សៀមរាប |
| 35 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវ៉ែល ស៊ែរវីស | សៀមរាប |
| 36 | ក្រុមហ៊ុន ដឹ អេរៀរី | សៀមរាប |
| 37 | ក្រុមហ៊ុន ម៉ុនស៊ូន អេស៊ាន ប៊ីស្រ្ទ | សៀមរាប |
| 38 | គ្រឹះស្ថាន ដាញប៊ីយ៉ន សឺវីស | សៀមរាប |
| 39 | ក្រុមហ៊ុន ដឹឃីតឈិនឆាយល | សៀមរាប |
| 40 | ក្រុមហ៊ុន អាហ្សូណា កាហ្វេធើរ៉ា | សៀមរាប |
| 41 | សណ្ឋាគារសុខាល័យអង្គរ រីហ្សេត និងស្ប៉ា | សៀមរាប |
| 42 | សណ្ឋាគារ ហិមា ប៊ូទិក | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 43 | ក្រុមហ៊ុន ឡាយ ហ្វូលយ៉ាណា អង្គរ ហូថេល ឯ.ក | សៀមរាប |
| 44 | ក្រុមហ៊ុន ហ្វូខឹស អេស៊ា អ៊ិនធើណេសិនណលត្រាវែល សឺវីស | សៀមរាប |
| 45 | ក្រុមហ៊ុន វេសធីវេន ខូឡិចហ្សិន | សៀមរាប |
| 46 | ក្រុមហ៊ុន សិប្បករអង្គរ | សៀមរាប |
| 47 | សណ្ឋាគារគោព្រៃ | សៀមរាប |
| 48 | ក្រុមហ៊ុន បាហ្វឹឡូធួរ (ខេមបូឌា) លីមីតធីត | សៀមរាប |
| 49 | ក្រុមហ៊ុន រ៉ូយ៉ាល់អង្គរ (សណ្ឋាគារសូហ្វីតែលអង្គរភូគីត្រាហ្គោហ្វ & ស្ប៉ារីហ្សត | សៀមរាប |
| 50 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 51 | សណ្ឋាគារស្ទឹងសៀមរាបថ្មី | សៀមរាប |
| 52 | ក្រុមហ៊ុន អេរីតាស II | សៀមរាប |
| 53 | ក្រុមហ៊ុន ទន្លេសាបថៅជាយ៉ា (ភោជនីយដ្ឋានទន្លេមេគង្គ) | សៀមរាប |
| 54 | ក្រុមហ៊ុន ទន្លេសាបថៅជាយ៉ា (ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 55 | ក្រុមហ៊ុន ទន្លេសាបថៅជាយ៉ា (ភោជនីយដ្ឋានទន្លេចតុមុខ) | សៀមរាប |
| 56 | ក្រុមហ៊ុន ទន្លេសាបថៅជាយ៉ា (អង្គរធីខេត្រាវែល ធួរ) | សៀមរាប |
| 57 | ក្រុមហ៊ុន ដំណាក់យៃភីថល ឯ.ក | សៀមរាប |
| 58 | សណ្ឋាគារ អូរៀនថល ដេ7 | សៀមរាប |
| 59 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 60 | ក្រុមហ៊ុន ហាប់ ហេង អ៊ិនវេសមេន ភីធីអ៊ី អិលធីឌី | សៀមរាប |
| 61 | ក្រុមហ៊ុន ញូវ រីវើរ សាយ | សៀមរាប |
| 62 | ក្រុមហ៊ុន ភូមិបៃតង (ខេមបូឌា) | សៀមរាប |
| 63 | ក្រុមហ៊ុន អេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 64 | សណ្ឋាគារ ឋានសួគ៌សុខា | កំពត |
| 65 | រមណីយដ្ឋានផ្ទេរសុខា | ព្រះសីហនុ |
| 66 | ក្រុមហ៊ុន ប្រូខន អ៊ិនវេសមេន ខូ អិលធីឌី | ព្រះសីហនុ |